# របាយការណ៍

## ស្ដីពីសមិទ្ធផលសម្រេចបានរយៈពេល៥ឆ្នាំ (២០១៨-២០២២) នៃការអនុវត្តយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៦នៃរដ្ឋសភា របស់រដ្ឋបាលខេត្តកោះកុង

### I. ស្ថានភាពភូមិសាស្ត្រ និងប្រជាសាស្ត្រ

ខេត្តកោះកុង មានទីតាំងស្ថិតនៅភាគនិរតីនៃប្រទេសកម្ពុជា ចម្ងាយ២៩០គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ និងមានព្រំប្រទល់ខាងកើតជាប់នឹងខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ ខាងលិច និងខាងត្បូងជាប់នឹងឈូងសមុទ្រថៃ និងប្រទេសថៃ ខាងជើងជាប់នឹងខេត្តពោធិ៍សាត់ និងមានផ្ទៃដីសរុប ១០.០៤៥,៥៨គ.ម² ចែកជា ១ក្រុង ៦ស្រុក ត្រូវជា ២៦ឃុំ ៣សង្កាត់ និង ១១៩ភូមិ។

នៅទូទាំងខេត្ត មានគ្រួសារសរុបចំនួន៣៤.៥៦៨គ្រួសារ មានប្រជាជនសរុប១៤៧.៨៣១នាក់ ស្រី ៧៤.០៤៦នាក់ មានដង់ស៊ីតេប្រជាជន ១៤នាក់/គម² និងមានប្រជាជនចម្រុះជាតិសាសន៍ដូចជា៖ ខ្មែរ ចិន ថៃ ចាម និងវៀតណាម។ មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋគឺ ធ្វើពាណិជ្ជកម្ម ផ្តល់សេវាកម្ម ដួញដូរ ធ្វើស្រែចម្ការ រកអនុផលព្រៃឈើ នេសាទ និងធ្វើកម្មកររោងចក្រ និងសំណង់។ ចំណូលជាមធ្យមប្រចាំឆ្នាំរបស់ប្រជាពលរដ្ឋម្នាក់ៗមានចំនួន១.៧៤៦ដុល្លារក្នុងឆ្នាំ២០២១ ដែលមានការកើនឡើងប្រមាណ៨,១២% បើប្រៀបធៀបទៅនឹងចំណូលប្រចាំឆ្នាំ២០១៧ ដែលមានចំនួន១.៤១៨ដុល្លារ និងអត្រាភាពក្រីក្រឆ្នាំ២០២១ មានចំនួន៧,៣% ថយចុះ៦,១៦% បើប្រៀបធៀបនឹងឆ្នាំ២០១៧ ដែលមានចំនួន១៣,៤៦%។ ចំពោះទំហំសេដ្ឋកិច្ចខេត្តទាំងមូលមានចំនួនប្រមាណ២៨២លានដុល្លារ ស្មើនឹង១,០៣%នៃសេដ្ឋកិច្ចជាតិ។

### II. សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ

ដោយអនុវត្តតាមគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល គណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត គណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ បានអនុវត្តយ៉ាងល្អប្រសើរ ដោយបានថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ជូនប្រជាពលរដ្ឋ និងភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិបានយ៉ាងល្អប្រសើរដោយពុំមានបញ្ហាអសន្តិសុខអ្វីកើតមានឡើយ។

## III. វឌ្ឍនភាពការងារ និងសមិទ្ធផលសំខាន់ៗ

### ១.ការផ្តល់សេវាសាធារណៈ

បច្ចុប្បន្ន ខេត្តកោះកុង បាននឹងកំពុងជំរុញ លើកកម្ពស់ការផ្តល់សេវាសាធារណៈជូនដល់ប្រជាពលរដ្ឋ តាមរយៈអង្គភាពច្រកចេញ-ចូលតែមួយនៅសាលាខេត្ត និងនៅតាមការិយាល័យ និងយន្តការច្រកចេញ-ចូលតែមួយ ក្រុង ស្រុក ឃុំ សង្កាត់ សរុបមានចំនួន ៣៧កន្លែង ហើយអង្គភាពច្រកចេញ-ចូលតែមួយនៃរដ្ឋបាលខេត្ត បានផ្តល់សេវាជូនប្រជាពលរដ្ឋក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះ បានចំនួន២០.៧៧៥សេវា (ម្ភៃពាន់ ប្រាំពីររយចិតសិបប្រាំ) និងបានប្រមូលថវិកាសរុបបានចំនួន៣.៣២៧.៩៩៦.១៥២រៀល (បីប៊ីលាន បីរយម្ភៃប្រាំពីរលាន ប្រាំបួនរយកៅសិបប្រាំមួយពាន់ មួយរយហាសិបពីររៀល)។

### ២.វិស័យសុខាភិបាល

- សេវាសុខាភិបាលឯកជន មានសរុបចំនួន១២០កន្លែង រួមមាន៖ បន្ទប់ពិគ្រោះស្ត្រីមានផ្ទៃពោះ ៣២កន្លែង បន្ទប់ថែទាំជំងឺ៤១កន្លែង បន្ទប់ពិគ្រោះព្យាបាលជំងឺ៤០កន្លែង បន្ទប់ពិគ្រោះព្យាបាលជំងឺមាត់ ធ្មេញ០៥កន្លែង មន្ទីរសំរាកព្យបាល០១កន្លែង មន្ទីរព្យាបាលជំងឺមាត់ធ្មេញ០១កន្លែង និងមានអគារនិងម៉ាស៊ីនផលិតអុកស៊ីសែនចំនួន១ ដែលជាអំណោយដ៏ថ្លៃថ្លារបស់ឯកឧត្តមបណ្ឌិត ហ៊ុន ម៉ាណែត ។
- អ្នកវិជ្ជមានចំនួន ៦.០៣៩នាក់ ស្រី ៣.៤៥០នាក់
- អ្នកជាសះស្បើយ ចំនួន ៥.៩៧២នាក់ ស្រី ៣.៤០៧នាក់
- អ្នកជំងឺស្លាប់ដោយសារវីរុសកូវីដ-១៩ សរុបចំនួន៦៧នាក់ ស្រី៤៣នាក់
- បានប្រគល់ប្រាក់ឧបត្ថម្ភជូនគ្រួសារសព សរុបចំនួន៦៧គ្រួសារ ស្មើនឹង១៥៥.០០០.០០០រៀល
- ប្រជាពលរដ្ឋបានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសទី១ ចំនួន៩៨.២១១នាក់ ស្រី៤៦.៧៩៣នាក់
- ប្រជាពលរដ្ឋបានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសទី២ ចំនួន៩៣.៤២៥នាក់ ស្រី៤៤.២២៨នាក់
- កុមារ និងយុវវ័យចាប់ពីអាយុ១២ឆ្នាំ ដល់១៧ឆ្នាំ បានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសទី១ ចំនួន១៦.២០៥នាក់ ស្រី ៧.៨៣៧នាក់
- កុមារ និងយុវវ័យចាប់ពីអាយុ១២ឆ្នាំ ដល់១៧ឆ្នាំ បានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសទី២ ចំនួន១៥.៧១២នាក់ ស្រី ៧.៦១៩នាក់
- កុមារចាប់ពីអាយុ៦ឆ្នាំ ដល់អាយុ១២ឆ្នាំ បានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសទី១ ចំនួន ១៧.៨៥៩នាក់ ស្រី ៨.៧២៧នាក់
- កុមារចាប់ពីអាយុ៦ឆ្នាំ ដល់អាយុ១២ឆ្នាំ បានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសទី២ ចំនួន ១៧.៥៩២នាក់ ស្រី ៨.៦៦៧នាក់
- កុមារ អាយុ៥ឆ្នាំ បានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសទី១ ចំនួន៣.៣៨៧នាក់ ស្រី ១.៥៧៩នាក់
- កុមារ អាយុ៥ឆ្នាំ បានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសទី២ ចំនួន២.៦០០នាក់ ស្រី១.២៨១នាក់
- កុមារអាយុ៣ឆ្នាំ ដល់ក្រោម៥ឆ្នាំ បានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសទី១ ចំនួន៤.០៣៨នាក់ ស្រី ២.០៨៣នាក់

- កុមារ អាយុ៣ឆ្នាំ ដល់ក្រោម៥ឆ្នាំ បានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសទី២ ចំនួន២.៣៩៣នាក់ ស្រី១.២៤៤នាក់
- ប្រជាជន បានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសទី៣ចំនួន៩២.៩១១នាក់ ស្រី ៤៤.៨៩៦នាក់
- ប្រជាជន បានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសទី៤ចំនួន២៨.៧០០នាក់ ស្រី១៤.២១៩នាក់
- ប្រជាជន បានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសទី៥ ចំនួន ១១.១១៦នាក់ ស្រី ៥.២៥៦នាក់
- ប្រជាពលរដ្ឋ ដែលបានចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដូសទី៦ ចំនួន១.៨៧៧នាក់ ស្រី៤៧៤នាក់

| ល.រ | ការបរិយាយ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | អគារឃ្លាំងសម្ភារ ២ជាន់ ៧x៦ ម៉ែត្រ | ខ្នង | ០ | ០ | ០ | ១ | ០ | ១ |
| ២ | អគារម៉ាស៊ីនផលិតអុកស៊ីសែន (២០ x ១១,៤ម) | ខ្នង | ០ | ០ | ០ | ១ | ០ | ១ |
| ៣ | អគារសង្គ្រោះបន្ទាន់ជាន់ផ្ទាល់ដី ប២៤,៧០ម ទ១១,៣០ម | ខ្នង | ០ | ១ | ០ | ០ | ០ | ១ |
| ៥ | អគារសម្រាប់ជនអនាថាជាន់ផ្ទាល់ដី | ខ្នង | ០ | ០ | ០ | ០ | ១ | ១ |
| ៦ | ផ្លូវចូលមន្ទីរពេទ្យក្រាលកៅស៊ូ | ម | ០ | ០ | ០ | ០ | ៦៦ | ៦៦ |
| ៧ | មន្ទីរពេទ្យបង្អែកខេត្តទទួលបានជ័យលាភី អង្គភាពផ្តល់សេវាសាធារណៈគំរូចំណាត់ថ្នាក់លេខ១ប្រចាំឆ្នាំក្នុងសំណុំសកម្មភាពផ្តល់សេវាកម្រិត២ | លើក | ពុំមានការប្រឡង | ១ | ពុំមានការប្រឡង | ពុំមានការប្រឡង | ពុំមានការប្រឡង | ១ |
| ៨ | មន្ទីរពេទ្យបង្អែកស្រែអំបិលទទួលបានជ័យលាភី ជាមន្ទីរពេទ្យបង្អែកដែលផ្តល់សេវាសំណុំសកម្មភាពបង្គ្រប់កម្រិត១ ចំណាត់ថ្នាក់លេខ ៦ | លើក | ពុំមានការប្រឡង | ១ | ពុំមានការប្រឡង | ពុំមានការប្រឡង | ពុំមានការប្រឡង | ១ |
| ៩ | អគារសម្រាកមុន និងក្រោយសម្រាលនៅមណ្ឌលសុខភាព | ខ្នង | ១១ | ០ | ០ | ១ | ១ | ១៣ |
| ១០ | ប៉ុស្តិ៍សុខភាព | ទីតាំង | ១០ | ០ | ១ | ០ | ១ | ១២ |
| ១១ | មណ្ឌលសុខភាព | ទីតាំង | ៩ | ០ | ៤ | ០ | ០ | ១៣ |
| ១២ | អគារស្នាក់នៅរបស់បុគ្គលិកប៉ុស្តិ៍សុខភាព | ខ្នង | ០ | ០ | ១ | ០ | ០ | ១ |
| ១៣ | ឡដុតកាកសំណល់វេជ្ជសាស្ត្រ | ឡ | ១៣ | ០ | ០ | ០ | ២ | ១៥ |

**៣.ការងារអប់រំ យុវជន និងកីឡា**

សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចគត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ដែលបានផ្តល់នូវចំណងដៃដ៏ថ្លៃថ្លានូវអគារសិក្សា អគារស្នាក់នៅ ទីចាត់ការ អគារកាត់ដេរ និងសាលសហសិក្សា សរុបចំនួន៦៨ខ្នង ស្មើនឹង៥៥៨បន្ទប់ ជូនដល់សិស្សានុសិស្សសម្រាប់រៀនសូត្រ នៅទូទាំងខេត្តកោះកុង ដើម្បីលើកស្ទួយវិស័យធនធានមនុស្ស។

| ល.រ. | ការបរិយាយ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | អគារសិក្សាទូទាំងខេត្ត | ខ្នង | ១០ | ៩ | ៣ | ១០ | ៩ | ៤១ |
| | ចំនួនបន្ទប់ | បន្ទប់ | ៩០ | ៨០ | ២២ | ៩០ | ៨០ | ៣៦២ |
| **អគារសិក្សាគ្រប់កម្រិត** | | | | | | | | |
| ១ | អគារសិក្សាវិទ្យាល័យ | ខ្នង | ១ | ៣ | ០ | ១ | ៣ | ៨ |
| | ចំនួនបន្ទប់ | បន្ទប់ | ១៥ | ១៦ | ០ | ១៥ | ១៦ | ៦២ |
| ២ | អគារសិក្សាអនុវិទ្យាល័យ | ខ្នង | ១ | ១ | ១ | ១ | ១ | ៥ |
| | ចំនួនបន្ទប់ | បន្ទប់ | ១៨ | ១២ | ១២ | ១៨ | ១២ | ៧២ |
| ៣ | អគារសិក្សាបឋមសិក្សា | ខ្នង | ៨ | ៥ | ២ | ៨ | ៥ | ២៨ |
| | ចំនួនបន្ទប់ | បន្ទប់ | ៥៧ | ៥២ | ១០ | ៥៧ | ៥២ | ២២៨ |
| ៤ | អគារផ្ទះស្នាក់គ្រូបង្រៀន | ខ្នង | ៣ | ២ | ១ | ៣ | ២ | ១១ |
| | ចំនួនបន្ទប់ | បន្ទប់ | ៤៦ | ៤០ | ៣ | ៤៦ | ៤០ | ១៧៥ |
| ៥ | អគារបំណិនជីវិត | ខ្នង | ០ | ០ | ០ | ០ | ៤ | ៤ |
| | ចំនួនបន្ទប់ | បន្ទប់ | ០ | ០ | ០ | ០ | ៨ | ៨ |
| ៦ | របងវិទ្យាល័យ | ទីតាំង | ០ | ០ | ០ | ១ | ០ | ១ |
| ៧ | របងអនុវិទ្យាល័យ | ទីតាំង | ១ | ០ | ០ | ០ | ០ | ១ |
| ៨ | របងសាលាបឋមសិក្សា | ទីតាំង | ៣ | ២ | ០ | ០ | ១ | ៦ |
| ៩ | ខ្លោងទ្វាវិទ្យាល័យ | ទីតាំង | ០ | ០ | ១ | ០ | ០ | ១ |
| ១០ | ខ្លោងទ្វាអនុវិទ្យាល័យ | ទីតាំង | ០ | ០ | ១ | ០ | ០ | ១ |
| ១១ | ខ្លោងទ្វាសាលាបឋមសិក្សា | ទីតាំង | ៥ | ២ | ១ | ០ | ០ | ៨ |
| ១២ | ផ្លូវបេតុង | កន្លែង | ៣ | ០ | ០ | ០ | ០ | ៣ |
| ១៣ | ទីលានកីឡាបាល់ទាត់ | ទីតាំង | ៣ | ១ | ២ | ០ | ០ | ៦ |
| ១៤ | ទីលាន់កីឡាបាល់ទះ | ទីតាំង | ៤ | ០ | ០ | ០ | ០ | ៤ |
| ១៥ | បង្គន់អនាម័យ | ខ្នង | ៥ | ៥ | ៣៦ | ៣៦ | ០ | ៨២ |
| ១៦ | កន្លែងលាងសម្អាតដៃ | ទីតាំង | ០ | ០ | ២២ | ០ | ០ | ២២ |
| ១៧ | ទីលានហាត់ប្រាណ | ទីតាំង | ០ | ០ | ២ | ០ | ០ | ២ |
| **កីឡាដែលទទួលបានពានរង្វាន់ និងប្រភេទពានរង្វាន់កម្រិតថ្នាក់ជាតិ** | | | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ១ | កីឡាបាល់ទាត់ | ក្រុម | ២ | ២ | ០ | ០ | ១ | ៥ |
| | មេដាយប្រាក់ | គ្រឿង | ១ | ១ | ០ | ០ | ១ | ៣ |
| | មេដាយសំរឹទ្ធ | គ្រឿង | ១ | ១ | ០ | ០ | ០ | ២ |
| ២ | កីឡាហែលទឹក | ក្រុម | ១ | ០ | ០ | ០ | ១ | ២ |
| | មេដាយមាស | គ្រឿង | ១ | ០ | ០ | ០ | ១ | ២ |
| | មេដាយប្រាក់ | គ្រឿង | ២ | ០ | ០ | ០ | ២ | ៤ |
| | មេដាយសំរឹទ្ធ | គ្រឿង | ០ | ០ | ០ | ០ | ១ | ១ |
| ៣ | កីឡាម៉ូតូទឹក | នាក់ | ០ | ០ | ០ | ០ | ២ | ២ |
| | មេដាយមាស | គ្រឿង | ០ | ០ | ០ | ០ | ១ | ១ |
| | មេដាយប្រាក់ | គ្រឿង | ០ | ០ | ០ | ០ | ១ | ១ |
| ៤ | កីឡាតៃក្វាន់ដូរ | នាក់ | ០ | ០ | ០ | ០ | ២ | ២ |
| | មេដាយសំរឹទ្ធ | គ្រឿង | ០ | ០ | ០ | ០ | ២ | ២ |
| ៥ | កីឡាលើកដុំដែក | នាក់ | ០ | ០ | ០ | ០ | ១ | ១ |
| | មេដាយសំរឹទ្ធ | គ្រឿង | ០ | ០ | ០ | ០ | ១ | ១ |
| ៦ | កីឡាទូកក្ដោង | នាក់ | ០ | ០ | ០ | ០ | ២ | ២ |
| | មេដាយប្រាក់ | គ្រឿង | ០ | ០ | ០ | ០ | ១ | ១ |
| | មេដាយសំរឹទ្ធ | គ្រឿង | ០ | ០ | ០ | ០ | ១ | ១ |
| ៧ | ចូលរួមប្រណាំងទូកនាគ ទទួលបានចំណាត់ថ្នាក់ | លេខ | ១ | ២ | ៤ | ៤ | ២ | ៥ |
| ៨ | ចូលរួមប្រកួតប្រជែញធុរកិច្ចជាតិសម្រាប់យុវជន ទទួលបានចំណាត់ថ្នាក់ | លេខ | ០ | ០ | ០ | ៣ | ១ | ២ |
| ៩ | ចូលរួមប្រកួតក្រុមយុវជនជដែកដេញដោល | លេខ | ០ | ០ | ០ | ០ | ១ | ១ |
| **ក្របខ័ណ្ឌចេញថ្មី និងផ្លាស់ចូល (២៧៩នាក់)** | | | | | | | | |
| ១ | គ្រូបង្រៀនកម្រិតឧត្តម | នាក់ | ២៤ | ២១ | ០ | ២០ | ០ | ៦៥ |
| ២ | គ្រូបង្រៀនកម្រិតមូលដ្ឋាន | នាក់ | ១៩ | ១២ | ១១ | ៣ | ០ | ៤៥ |
| ៣ | គ្រូអប់រំកាយ និងកីឡា | នាក់ | ២ | ៤ | ០ | ០ | ០ | ៦ |
| ៤ | គ្រូបង្រៀនកម្រិតបឋម | នាក់ | ៤៦ | ៣៥ | ៣៨ | ១៤ | ០ | ១៣៣ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | សិក្សា | | | | | | | |
| ៥ | គ្រូមត្តេយ្យសិក្សា | នាក់ | ៥ | ៥ | ៦ | ៣ | ០ | ១៩ |
| ៦ | ផ្លាស់ និងពង្រាយចូល | នាក់ | ៦ | ០ | ១ | ៤ | ០ | ១១ |
| ចំនួនសិស្សសរុបនៅដើមឆ្នាំសិក្សា | | | | | | | | |
| ១ | សិស្សបឋមសិក្សា | នាក់ | ១៦.៧៥៣ | ១៦.៧២៥ | ១៦.២២៥ | ១៦.៥៨៥ | ១៧.២០៥ | ១៧.២០៥ |
| ២ | សិស្សមធ្យមសិក្សាបឋមភូមិ | នាក់ | ៤.៦៨០ | ៤.៨៧៣ | ៥.១៣១ | ៥.៤១២ | ៥.៧០៤ | ៥.៧០៤ |
| ៣ | សិស្សមធ្យមសិក្សាទុតិយភូមិ | នាក់ | ២.៤០០ | ២.៥២២ | ២.៦៦៣ | ២.៩៦៨ | ៣.១៣១ | ៣.១៣១ |
| **សិស្សដែលបានប្រឡងជាប់ និងទទួលបានអាហារូបករណ៍** | | | | | | | | |
| ១ | សិស្សទទួលបាននិទ្ទេសA | នាក់ | ០ | ១ | ០ | ៤ | ៥ | ១០ |
| ២ | បេក្ខជនប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ | នាក់ | ១.២២៥ | ១.១៣៧ | ជាប់ជាស្ពាពរ | ១.៣២៧ | ១.៤៥០ | ៥.១៣៩ |
| ៣ | បេក្ខជនប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ | នាក់ | ៥០៤ | ៤៧៨ | ជាប់ជាស្ពាពរ | ៣៩៤ | ៥៧២ | ១៩៤៨ |
| ៤ | សិស្សទទួលអាហារូបករណ៍ពីថវិកាកម្មវិធីរបស់រដ្ឋ (PB) | កន្លែង | ១.៦៣៣ | ១.៦៥៧ | ១.៦៩២ | ២.០២២ | ១.៧១០ | ៨.៧១៤ |
| ៥ | សិស្សទទួលអាហារូបករណ៍ពីសហគមន៍អឺរ៉ុប(EU) | កន្លែង | ០ | ០ | ៣៣០ | ៣៣០ | ១០០ | ៧៦០ |
| ៦ | សិស្សទទួលអាហារូបករណ៍នៅឧត្តមសិក្សា ពីសកលវិទ្យាល័យនានា | កន្លែង | ៤៥ | ៣២ | ២៩ | ០ | ២៣ | ១២៩ |
| **ស្ថិតិក្រុមយុវជន និងកីឡា** | | | | | | | | |
| ១ | ស្ថិតិក្រុមកាយរឹទ្ធិ | នាក់ | ៤០៦ | ៨៤៨ | ០ | ០ | ៥៨៤ | ១.៨៣៨ |
| ២ | ស្ថិតិក្រុមប្រឹក្សាកុមារកម្ពុជា | នាក់ | ១២.៥៧៧ | ១១.៦២៦ | - | - | ១២.៤២២ | ៣៦.៦២៥ |
| ៣ | ស្ថិតិក្រុមប្រឹក្សាយុវជនកម្ពុជា | នាក់ | ២.៥១២ | ២.៦១២ | - | - | ៣.៩៨៧ | ៩.១១១ |
| **ការងារអប់រំក្រៅប្រព័ន្ធ** | | | | | | | | |
| ១ | គ្រូជាប់កិច្ចសន្យាកម្មវិធីអប់រំក្រៅប្រព័ន្ធ | នាក់ | ១២៦ | ១០០ | ៦៣ | ៤៥ | ៦២ | ៣៩៦ |
| ២ | ថ្នាក់កម្មវិធីអប់រំក្រៅប្រព័ន្ធ | ថ្នាក់ | ១២០ | ១០០ | ៦៣ | ៤៥ | ៥៨ | ៣៨៦ |
| ៣ | សិស្សកម្មវិធីអប់រំក្រៅប្រព័ន្ធដែលបានឆ្លងវគ្គបណ្តុះបណ្តាល | នាក់ | ៩៨១ | ៧០០ | ៦៤៦ | ៥៨៧ | ៨៣៩ | ៣.៧៥៣ |

## ៤. ការងារទេសចរណ៍

| ល.រ | ការបរិយាយ | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|---|
| ១ | រមណីយដ្ឋានទេសចរណ៍ | ១២ | +១ | +0 | +0 | +0 | ១៣ |
| ២ | សណ្ឋាគារ | ១០ | +0 | ២ | ២ | ១ | ១៥ |
| | ចំនួនបន្ទប់ | ៨០៩ | 0 | ១៨ | ២៧ | ៩ | ៨៦៣ |
| ៣ | ផ្ទះភ្ញៀវ | ៩០ | ៦ | ៦ | ១ | 0 | ១០៣ |
| | ចំនួនបន្ទប់ | ៨៥៤ | ១៧១ | ១៧២ | ២២ | 0 | ១.២១៩ |
| ៤ | ភោជនីយដ្ឋាន អាហារដ្ឋាន | ៨៦ | ១៣ | ៥៦ | 0 | 0 | ១៥៥ |
| | ចំនួនកៅអី | ២.៥៦០ | ១.១២០ | ១.៦៥១ | 0 | 0 | ៥.៣៣១ |
| ៥ | ខារ៉ាអូខេ | ២៨ | ១ | 0 | 0 | 0 | ២៩ |
| | ចំនួនបន្ទប់ | ១០៥ | ១៧ | 0 | 0 | 0 | ១២២ |
| ៦ | ក្លឹបកម្សាន្ត | ២ | 0 | 0 | 0 | 0 | ២ |
| | ចំនួនកៅអី | ១០០ | 0 | 0 | 0 | 0 | ១០០ |
| ៧ | បៀហ្គាឌិន | 0 | ២ | ៣ | 0 | 0 | ៥ |
| | ចំនួនកៅអី | 0 | ១០០ | ១៥០ | 0 | 0 | ២៥០ |
| ៨ | ម៉ាស្សា | ១៥ | 0 | ២១ | 0 | 0 | ៣៦ |
| | ចំនួនគ្រែ | ៦៤ | 0 | ៣៦ | 0 | 0 | ១០០ |
| ៩ | ក្លឹបប៊ុកប៊ីយ៉ែរ | ១ | ១ | 0 | 0 | ១ | ៣ |
| | ចំនួនតាប | ៥ | ៥ | 0 | 0 | ៣ | ១៣ |
| ១០ | ហាងកាហ្វេ | ១០ | ១ | ៥ | 0 | ២ | ១៨ |
| | ចំនួនកៅអី | ១៩៦ | ២៩ | ២០ | 0 | ២០ | ២៦៥ |
| ១១ | ដឹកជញ្ជូនទេសចរណ៍ផ្លូវទឹក | ៣ | 0 | 0 | 0 | 0 | ៣ |
| | ចំនួនកៅអី | ៣០ | 0 | 0 | 0 | 0 | ៣០ |
| ១២ | ដឹកជញ្ជូនទេសចរណ៍ផ្លូវគោក | ២ | 0 | 0 | 0 | 0 | ២ |
| | ចំនួនកៅអី | ៨ | 0 | 0 | 0 | 0 | ៨ |
| ១៣ | អាជីវកម្មកីឡាមុជទឹក | 0 | ២ | 0 | 0 | 0 | ២ |
| ១៤ | សហគមន៍ទេសចរណ៍ | ៥ | 0 | 0 | 0 | 0 | ៥ |

- មានឆ្នេរសមុទ្រប្រវែងប្រមាណ ២១៥គីឡូម៉ែត្រ នៃប្រវែងឆ្នេរសមុទ្រសរុប ៤៤០គីឡូម៉ែត្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលបានជាប់ជាសមាជិកក្លឹបឆ្នេរសមុទ្រស្អាតបំផុតនៅលើពិភពលោក និងត្រូវបានប្រសិទ្ធនាមថា តារារះនាទិសនិរតី ក្នុងនោះ ឆ្នេរតារាសាគរ ទទួលបានចំណាត់ថ្នាក់លេខ២ និងឆ្នេរចាំយាម ទទួលបានចំណាត់ថ្នាក់លេខ៣ នៃជ័យលាភីប្រឡងឆ្នេរស្អាត ខេត្តតំបន់មាត់សមុទ្រ

- មានតំបន់អេកូទេសចរណ៍ធម្មជាតិព្រៃកោងកាងទំហំសរុប ៦២.០០០ហិកតា នៅទូទាំងខេត្ត និងតំបន់អេកូទេសចរណ៍ធម្មជាតិ នៅតាមបណ្តាក្រុង ស្រុកមួយចំនួនទៀត ដូចជានៅតាមដងផ្លូវជាតិលេខ៤៨ នៅជីផាត តំបន់អារ៉ែង ជាដើម។ល។
- មានអគារផលិតផលិតផលសហគមន៍ (មានបំពាក់សម្ភារឧបករណ៍សម្រាប់ផលិត ផលិតផលសហគមន៍តំបន់ការពារធម្មជាតិពាមក្រសោប)
- មានមណ្ឌលព័ត៌មានសហគមន៍ (សហគមន៍តំបន់ការពារធម្មជាតិពាមក្រសោប)
- មានកំពង់ផែខ្នាតតូចសម្រាប់ភ្ញៀវទេសចរចុះទូក នៅសហគមន៍អេកូទេសចរណ៍តាតៃក្រោម
- រមណីយដ្ឋានទេសចរណ៍សំខាន់ៗក្នុងខេត្តមានចំនួន ១៣កន្លែង ក្នុងនោះរួមមាន៖

  ១-រមណីយដ្ឋានទេសចរណ៍កែច្នៃមានចំនួន ២កន្លែង
    - តំបន់អភិវឌ្ឍកោះកុង រីសត (L.Y.P.Group) ស្ថិតនៅភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា
    - តំបន់វិស្សមកាលតារាសាគរ ភូមិពាមកាយ ឃុំកោះស្តេច ស្រុកគិរីសាគរ

  ២-រមណីយដ្ឋាន ធម្មជាតិ វប្បធម៌ ប្រវត្តិសាស្ត្រមានចំនួន ១១កន្លែង
    - រមណីយដ្ឋាន ចេតីយ ឃុន ឆាង ស្ថិតនៅភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា
    - រមណីយដ្ឋាន ឆ្នេរប៉ាក់ខ្លង ស្ថិតនៅភូមិ១ ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា
    - បូជនីយដ្ឋាន ព្រះអង្គគោកធ្លក ស្ថិតនៅភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា
    - រមណីយដ្ឋានទេសចរណ៍ ព្រៃកោងកាងពាមក្រសោប ស្ថិតនៅភូមិពាមក្រសោប១ ឃុំពាមក្រសោប ស្រុកមណ្ឌលសីមា
    - រមណីយដ្ឋានអេកូទេសចរណ៍ តាតៃក្រោម ស្ថិតនៅភូមិអន្លង់វ៉ាក់ ឃុំតាតៃក្រោម ស្រុកកោះកុង
    - រមណីយដ្ឋានទេសចរណ៍ធម្មជាតិតំបន់ស្ទឹងអារ៉ែង ស្ថិតនៅភូមិជំនាប់ ឃុំជំនាប់ ស្រុកថ្មបាំង
    - រមណីយដ្ឋានទេសចរណ៍ ជីផាត ស្ថិតនៅភូមិជីផាត ឃុំជីផាត ស្រុកថ្មបាំង
    - តំបន់ប្រជុំកោះឆ្នេរ កោះស្តេច ស្ថិតនៅភូមិកោះស្តេច ឃុំកោះស្តេច ស្រុកគិរីសាគរ
    - ឆ្នេរកោះកុងក្រៅ និងតំបន់ជុំវិញស្រុកកោះកុង
    - រមណីយដ្ឋានទេសចរណ៍ ស្ទឹងពពក ស្ថិតនៅភូមិព្រះអង្គកែវ ឃុំដងពែង ស្រុកស្រែអំបិល
    - រមណីយដ្ឋាន ឆ្នេរនេសាទ ស្ថិតនៅភូមិនេសាទ ឃុំជ្រោយស្វាយ ស្រុកស្រែអំបិល។

### ៥.ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរបស់រដ្ឋបាលខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់

- **គម្រោងដែលប្រើប្រាស់ថវិការបស់រដ្ឋបាលខេត្ត**

| ល.រ | ការបរិយាយ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | ផ្លូវបេតុង | ខ្សែ | ១៤ | ១៥ | ១៣ | ១០ | ៤ | ៥៦ |
| | ប្រវែង | គ.ម | ២,៦៦ | ៩,៣៤ | ៤,១៥ | ៥,០៨ | ២,៥០ | ២៣,៧៣ |
| ២ | ផ្លូវក្រាលកៅស៊ូអាសេ | ខ្សែ | ០ | ១ | ២ | ៥ | ៥ | ១៣ |
| | ប្រវែង | គ.ម | ០ | ១,៥០ | ៣,៥៣ | ៥,០៤ | ៥,៩០ | ១៥,៩៧ |
| ៣ | ថែទាំផ្លូវក្រាលកៅស៊ូ | ខ្សែ | ១៧ | ០ | ០ | ០ | ២ | ១៩ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | ប្រវែង | គ.ម | ២១៥,៨៧ | ០ | ០ | ០ | ២,២៤ | ២១៦,១១ |
| ៤ | សាងសង់ផ្លូវក្រាលក្រួសក្រហម | ខ្សែ | ០ | ០ | ៦ | ០ | ០ | ៦ |
| | ប្រវែង | គ.ម | ០ | ០ | ៧,៥០ | ០ | ០ | ៧,៥០ |
| ៥ | ថែទាំផ្លូវក្រាលក្រួសក្រហម | ខ្សែ | ១៨ | ០ | ០ | ០ | ០ | ១៨ |
| | ប្រវែង | គ.ម | ៦០,៣០ | ០ | ០ | ០ | ០ | ៦០,៣០ |
| ៦ | លូកាត់ផ្លូវ | កន្លែង | ៥ | ០ | ២ | ១ | ១ | ៩ |
| ៧ | លូដោះទឹក | ខ្សែ | ១ | ១ | ៤ | ១ | ៤ | ១១ |
| | ប្រវែង | ម | ៣៣៥ | ៤១២ | ១.៦៨៧ | ១៥០ | ២.២៧៥ | ៥.០៥៩ |
| ៨ | ស្ពានប្រឡាយ និងលូ | ខ្សែ | ០ | ០ | ៣ | ០ | ៣ | ៦ |
| | ប្រវែង | ម | ០ | ០ | ៣.៩៥០ | ០ | ២.៧១០ | ៦.៦៦០ |
| ៩ | ស្ពាន | កន្លែង | ០ | ០ | ០ | ០ | ០ | ០ |
| ១០ | អណ្តូងស្នប់ | កន្លែង | ៥ | ០ | ០ | ០ | ០ | ៥ |
| ១១ | ស្រះ | កន្លែង | ១ | ០ | ០ | ០ | ០ | ១ |
| ១២ | សាងសង់អគារច្រកចេញចូលតែ១ | កន្លែង | ១ | ១ | ១ | ១ | ០ | ៤ |
| ១៣ | សាងសង់អគាររដ្ឋបាលឃុំ | កន្លែង | ០ | ៤ | ០ | ០ | ០ | ៤ |
| ១៤ | សាងសង់អគាររដ្ឋបាលខេត្ត | កន្លែង | ១ | ០ | ០ | ១ | ០ | ២ |
| ១៥ | រៀបចំសួនច្បារ | កន្លែង | ១ | ០ | ២ | ០ | ០ | ៣ |
| | ប្រវែង | ម | ០ | ៣៣៥ | ០ | ៩៥៨ | ០ | ១.២៩៦ |
| ១៦ | ជួសជុលសាលមហោស្រព | កន្លែង | ០ | ០ | ០ | ១ | ០ | ១ |
| ១៧ | រៀបចំសួនកុមារ | កន្លែង | ០ | ០ | ០ | ០ | ១ | ១ |

- បានសាងសង់ ជួសជុលទីលានផ្នូរសពយុទ្ធជនខេត្តកោះកុង ស្ថិតក្នុងក្រុងខេមរភូមិន្ទ (ក្នុងឆ្នាំ ២០២១) និង

- **គម្រោងដែលប្រើប្រាស់ថវិការបស់រដ្ឋបាលក្រុង ស្រុក**

| ល.រ | ការបរិយាយ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | ផ្លូវបេតុង | ខ្សែ | ១៤ | ៥ | ១០ | ៦ | ៥ | ៤០ |
| | ប្រវែង | គ.ម | ២,៥៣ | ១,២៥ | ២,១៦ | ១,៥៨ | ២ | ៩,៥២ |
| ២ | សាងសង់ផ្លូវក្រាលក្រួសក្រហម | ខ្សែ | ១ | ៥ | ០ | ១ | ០ | ៤ |
| | ប្រវែង | គ.ម | ៣,៥០ | ១,២៥ | ០ | ៣,៣០ | ០ | ១២,៥០ |
| ៣ | លូកាត់ផ្លូវ | កន្លែង | ១ | ១ | ០ | ៤ | ១១ | ១៧ |
| ៤ | លូដោះទឹក | ខ្សែ | ០ | ២ | ០ | ១ | ២ | ៥ |
| | ប្រវែង | ម | ០ | ៥០០ | ០ | ៣០០ | ៨០០ | ១.៦០០ |
| ៥ | សាងសង់ទំនប់បង្ហៀរ | ខ្សែ | ០ | ១ | ១ | ០ | ០ | ២ |

- **គម្រោងដែលប្រើប្រាស់ថវិការបស់ឃុំ សង្កាត់**

| ល.រ | ការបរិយាយ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|---|---|

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ១ | ផ្លូវបេតុង | ខ្សែ | ១២ | ១២ | ២៤ | ២៣ | ២៥ | ៩៦ |
| | ប្រវែង | គ.ម | ៣,២៥ | ២,៨០ | ៦,៤៥ | ៧,២០ | ៦,២៨ | ២៥,៩៨ |
| ២ | សាងសង់ផ្លូវក្រាលក្រួសក្រហម | ខ្សែ | ១៥ | ១៦ | ១២ | ១០ | ១៦ | ៦៩ |
| | ប្រវែង | គ.ម | ២៦,៥០ | ២៩,៥២ | ២៨,៦០ | ២៥ | ២៨,៥២ | ១៣៨,១៤ |
| ៣ | លូកាត់ផ្លូវ | កន្លែង | ៩ | ២ | ១១ | ១ | ១៧ | ៤០ |
| ៤ | លូដោះទឹក | ខ្សែ | ០ | ០ | ៥ | ១ | ១ | ៧ |
| | ប្រវែង | ម | ០ | ០ | ៦០៩ | ៣២ | ៧៧៩ | ១.៤២០ |
| ៥ | សំណង់ការពារហូរច្រោះ | កន្លែង | ១ | ០ | ០ | ០ | ០ | ១ |
| ៦ | ទំនប់បង្វៀរ | កន្លែង | ១ | ០ | ០ | ០ | ០ | ១ |
| ៧ | ស្រះ | កន្លែង | ២ | ៤ | ០ | ២ | ០ | ៨ |
| ៨ | ស្តារប្រឡាយ | ខ្សែ | ០ | ០ | ០ | ២ | ២ | ៤ |
| | ប្រវែង | ម | ០ | ០ | ០ | ១.៣៧៧ | ៣៩០ | ១.៧៦៧ |
| ៩ | អណ្តូង | កន្លែង | ៤ | ១០ | ០ | ០ | ០ | ១៤ |
| ១០ | ស្ពាន | កន្លែង | ១ | ០ | ០ | ០ | ១ | ២ |
| ១១ | សាលាមត្តេយ្យសហគមន៍ | កន្លែង | ១ | ០ | ០ | ០ | ០ | ១ |
| ១២ | សាងសង់កំពង់ផែ | កន្លែង | ០ | ០ | ០ | ១ | ០ | ១ |
| ១៣ | អគារមុន និងក្រោយសម្រាល | កន្លែង | ០ | ០ | ០ | ០ | ២ | ២ |

ជាមួយនឹងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធខាងលើ ខេត្តកោះកុង បាននឹងកំពុងសាងសង់ស្តូបអនុស្សាវរីយ៍នយោបាយឈ្នះ ឈ្នះ ស្ថិតក្នុងភូមិបឹងយុនឆាង សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ដែលដឹកនាំការសាងសង់ដោយសម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ។ ការសាងសង់ស្តូបអនុស្សាវរីយ៍នយោបាយឈ្នះ ឈ្នះ នេះ ក្នុងគោលបំណង រំលឹកដល់សារៈសំខាន់នៃសន្តិភាព សមិទ្ធផលនិងដំណើរការដែលបាននាំឱ្យមានសន្តិភាពតាមរយៈគោលនយោបាយឈ្នះ ឈ្នះ និងការបង្រួបបង្រួមជាតិ ព្រមទាំងគោរពនិងចារឹកទុកអំពីការលះបង់ ការដឹកនាំ និងភាពថ្លៃប្រឹតរបស់អគ្គមគ្គុទេសក៍ដឹកនាំ និងប្រតិបត្តិករឆ្នើមកម្ពុជា ដែលបាននាំមកនាំការផ្សះផ្សារជាតិ និងបញ្ចប់សង្គ្រាមស៊ីវិល ដោយគ្មានការបង្ហូរឈាម ហើយនាំមកនាំវិបុលភាព និងសន្តិភាពដល់ប្រទេសកម្ពុជា។ ស្តូបអនុស្សាវរីយ៍នយោបាយឈ្នះ ឈ្នះ ខេត្តកោះកុង នឹងក្លាយជាមជ្ឈមណ្ឌលមួយដែលផ្តល់នូវការរៀនសូត្រដល់ប្រជាជនជំនាន់ក្រោយ ទទួលស្គាល់ប្រវត្តិសាស្ត្រពិត និងបន្តអនុវត្តនយោបាយឈ្នះ ឈ្នះ ហើយនឹងក្លាយជាគោលដៅទេសចរណ៍ដែលមានលក្ខណៈប្រវត្តិសាស្ត្រ វប្បធម៌ និងទស្សនកិច្ចសិក្សាស្រាវជ្រាវនានា។ សមិទ្ធផលដ៏ថ្លៃថ្លានេះ នឹងផ្តល់នូវកិត្តិយស និងមុខមាត់ថ្មីបន្ថែមទៀត នាទិសនារតីលើទឹកដីខេត្តកោះកុង។

### ៦.ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- **ការបង្កបង្កើនផល**

| ល.រ | ឆ្នាំ | ផ្ទៃដីដាំដុះ(ហិកតា) | | | | បរិមាណផលនាំចេញ (តោន) |
|---|---|---|---|---|---|---|
| | | ស្រូវ | សៀងរួមផ្សំ | ឧស្សាហកម្ម | អចិន្ត្រៃយ៍ | |

| | | | | | | |
|---|---|---|---|---|---|---|
| ១ | ២០១៨ | ១០.៤១៧ | ៤៦២ | ១.២០១ | ៦០៨ | ៨.០២៣ |
| ២ | ២០១៩ | ៩.៨៣៥ | ៤៤៣ | ២០៣ | ១.០៨៥ | ៥.៥៩៩ |
| ៣ | ២០២០ | ១០.១៧៩ | ៣២៤ | ៧២ | ៦១៦ | ៦.៤៣៩ |
| ៤ | ២០២១ | ៩.៨២៧ | ២៨៣ | ១៩០ | ៤៧០ | ៩.២៧៧ |
| ៥ | ២០២២ | ១០.១៨៥ | ៣២៦ | ២៩៤ | ៤០០ | ៧.៩៨២ |
| **សរុប** | | **៥០.៤៤៣** | **១.៨៣៨** | **១.៩៦០** | **៣.១៧៩** | **៣៧.៣២០** |

- **ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារ និងកសិដ្ឋាន**

| ល.រ | ឆ្នាំ | ប្រភេទសត្វចិញ្ចឹម(ក្បាល) | | | | |
|---|---|---|---|---|---|---|
| | | គោ | ក្របី | ជ្រូក | ពពែ | សត្វស្លាប |
| ១ | ២០១៨ | ៨.៤៥៨ | ៩.៨៧៦ | ១១.៦៦៩ | ២៥៧ | ១០៧.៧១៧ |
| ២ | ២០១៩ | ៨.៦៥១ | ១០.២២៣ | ១២.៤២០ | ២៦២ | ១៤២.៦២៦ |
| ៣ | ២០២០ | ៩.៣៩០ | ១០.៥២៨ | ១៤.៧១១ | ៣២១ | ១៩៦.០៤៧ |
| ៤ | ២០២១ | ៩.៨៦៧ | ១១.២១៧ | ៣.០៣៥ | ៤៧២ | ២២២.៩២៥ |
| ៥ | ២០២២ | ១០.០៨០ | ១១.៤០០ | ៣.២២៣ | ៥៥១ | ២២៦.៨៤០ |
| **សរុប** | | **៤៦.៤៤៦** | **៥៣.២៤៤** | **៤៥.០៥៨** | **១.៨៦៣** | **៨៩៦.១៥៥** |

- **ការប្រមូល និងកែច្នៃផលនេសាទ**

| ល.រ | ឆ្នាំ | ផលនេសាទ(តោន) | | | ផលនេសាទកែច្នៃ | |
|---|---|---|---|---|---|---|
| | | ទឹកសាប | សមុទ្រ | វារីវប្បកម្ម | ផលកែច្នៃ(តោន) | ទឹកត្រី(លីត្រ) |
| ២ | ២០១៨ | ៣៩០ | ៥១.៣៧០ | ៣.៤០៨ | ២.១៥០ | ៧០.៧០០ |
| ៣ | ២០១៩ | ៥៧៧ | ៤៩.១៦០ | ៣.៧៦២ | ២.២២១ | ៥២.០០០ |
| ៤ | ២០២០ | ៧៥២ | ៥២.៥៤៩ | ៥.៤៣០ | ២.៣៥០ | ៦០.០០០ |
| ៥ | ២០២១ | ៤៥៥ | ៤៩.៣៥៥ | ១.៥៨០ | ១.៩១៥ | ៤៣.០០០ |
| ៦ | ២០២២ | ៤៧០ | ៤៨.៣៨៥ | ៨.៣៨០ | ២.១០៥ | ១៦.១៨០ |
| **សរុប** | | **២.៦៤៤** | **២៥០.៨១៩** | **២២.៥៦០** | **១០.៧៤១** | **២៤១.៨៨០** |

- **ការថែទាំកូនឈើ និងដាំកូនឈើ**

| ល.រ | ឆ្នាំ | បណ្តុះកូនឈើ និងថែទាំ (ដើម) | ដាំកូនឈើ និងចែកចាយ (ដើម) |
|---|---|---|---|

| | | | |
|---|---|---|---|
| ១ | ២០១៨ | ២.៩៣០ ដើម | ១.២១០ ដើម |
| ២ | ២០១៩ | ៥.១៥៨ ដើម | ៨៧០ ដើម |
| ៣ | ២០២០ | ១៥.១៤៩ ដើម (សហគមន៍ ៨ ៣៨០ ដើម) | ៨៨៥ ដើម (សហគមន៍ ៥០០ ដើម) |
| ៤ | ២០២១ | ៥.១៩៩ ដើម | ២៥៥ ដើម |
| ៥ | ២០២២ | ៤.៦១៨ ដើម | ៣៨១ ដើម |
| **សរុប** | | **៣៣.០៥៤ ដើម** | **៣.៦០១ ដើម** |

- **ការងារកៅស៊ូ**
  - ផ្ទៃដីដាំកៅស៊ូគ្រួសារ មានចំនួនសរុប ១.៦៤៩,៤ ហិកតា
  - ផ្ទៃដីប្រមូលផល មានចំនួនសរុប ១.៣២៩,៤ ហិកតា
  - ទិន្នផលជាមធ្យម ០,៦៩៥ តោន/ហិកតា
  - តម្លៃជ័រចាន ៣.១០០៛/គីឡូក្រាម។
- **តំបន់អភិរក្សធនធានជលផលមានចំនួន ១១ កន្លែង៖**
  - តំបន់អភិរក្សអណ្ដើកហ្លួង និងក្រពើត្រី មានទំហំ២.៨១៨ហ.ត នៅស្រុកស្រែអំបិល
  - តំបន់អភិរក្សគ្រែងឈាម មានទំហំ៤០០ហ.ត នៅឃុំថ្មស ស្រុកបូទុមសាគរ
  - តំបន់អភិរក្សត្រីពងកូនពយអន្ទង់ មានទំហំ២០.៥៩៤ហ.ត នៅឃុំជ្រោយស្វាយ ស្រុកស្រែអំបិល
  - តំបន់អភិរក្សត្រីពងកូនពយម្កាក់ មានទំហំន១១.៦៧១ហ.ត នៅឃុំជ្រោយស្វាយ ស្រុកស្រែអំបិល
  - តំបន់អភិរក្សត្រីពងកូនពយថ្មធំ មានទំហំ១១.១៤៩ហ.ត នៅឃុំជ្រោយស្វាយ ស្រុកស្រែអំបិល
  - តំបន់អភិរក្សគ្រែងឈាម មានទំហំ៥ហ.ត នៅឃុំដីឥក្រោម ស្រុកស្រែអំបិល
  - តំបន់អភិរក្សត្រីពងកូនក្នុងសហគមន៍នេសាទតំបន់ឆ្នេរសមុទ្រតាមាយ មានទំហំ១០ហ.ត នៅឃុំអណ្តូងទឹក ស្រុកបូទុមសាគរ
  - តំបន់ស្មៅសមុទ្រ (ឡាំប៉ក់ ជ្រោយប្រស់) មានទំហំ២៣៦ហ.ត និងវាលអេក មានទំហំ ៣៣៩ហ.ត នៅឃុំជ្រោយប្រស់ ស្រុកកោះកុង
  - តំបន់អភិរក្សក្តាមជ័រ មានទំហំ៥០ហ.ត នៅឃុំព្រែកខ្សាច់ ស្រុកគិរីសាគរ
  - តំបន់អភិរក្សផ្កាថ្ម ប្រជុំកោះខ្មោច និងកោះអណ្តើក មានទំហំសរុបចំនួន១៤ហ.ត នៅឃុំកោះស្តេច ស្រុកគិរីសាគរ
  - តំបន់គ្រប់គ្រងដែនជម្រកសុវត្ថិភាពត្រីកាម៉ុងនៅពាមក្រសោប មានទំហំ១.២៨៣ហ.ត នៅឃុំពាមក្រសោប ស្រុកមណ្ឌលសីមា និងឃុំកោះកាពិ ស្រុកកោះកុង ។
- **ការងារដែននេសាទ**
  - ដាំកូនកោងកាង បានចំនួន ៣៧៣.០០០ដើម លើផ្ទៃដី ៣៧,៣០ហ.ត និងបណ្តុះកូនកោងកាងបានចំនួន ៩១.២០០ដើម នៅឃុំជ្រោយស្វាយ ឃុំដីឥក្រោម ឃុំអណ្តូងទឹក និងឃុំថ្មស។
- **ការងារវារីវប្បកម្ម**

- ការចិញ្ចឹមត្រីសមុទ្រ តាមបែ មានចំនួន១៥៩បែ មានផ្ទៃក្រឡា ១.៣៩៥ម$^2$
- ការចិញ្ចឹមត្រីសមុទ្រ តាមស្រះ មានចំនួន៦ស្រះ មានផ្ទៃក្រឡា ១៥.០០០ម$^2$
- ការចិញ្ចឹមគ្រំ និងគ្រែងឈាមតាមបែបវិបុលវប្បកម្ម រួមមាន៖ ចិញ្ចឹមគ្រំចំពុះទា មានចំនួន៣កន្លែង ស្ថិតនៅឃុំពាមក្រសោប ឃុំកោះកាពិ និងឃុំជ្រោយប្រស់។

- **សមាគមកែច្នៃផលិតផលជលផលក្នុងខេត្តមានចំនួន៣កន្លែង៖**
  - សមាគម បង្គាក្រៀម មានចំនួន២ នៅឃុំពាមក្រសោបចំនួន១ និងនៅឃុំថ្មសចំនួន១
  - សមាគមផលិតទឹកត្រី មានចំនួន១ នៅឃុំជីខក្រោម ស្រុកស្រែអំបិល។
- **សហគមន៍កសិកម្មមានចំនួន៣សហគមន៍ រួមមាន ៖**
  - សហគមន៍កសិកម្មអង្គរភ្នំខ្លង ចុះបញ្ជីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៤ ដែលផ្តោតសំខាន់ទៅលើមុខរបរចំនួន៣ ៖ មុខរបរទីផ្សារ មុខរបរផ្គត់ផ្គង់ និងមុខរបរឥណទាន
  - សហគមន៍កសិកម្មសាមគ្គីធម៌ ចុះបញ្ជីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ ដែលផ្តោតសំខាន់ទៅលើមុខរបរចំនួន៣ ៖ មុខរបរឥណទាន មុខរបរទីផ្សារ និងមុខរបរប្រើប្រាស់រួមគ្នា
  - សហគមន៍កសិកម្មដំណាំម្រេចអារ៉ែង ចុះបញ្ជីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ ផ្តោតសំខាន់ទៅលើមុខរបរចំនួន២៖ មុខរបរឥណទាន និងមុខរបរទីផ្សារក្នុងគោលបំណងស្វែងរកទីផ្សារ និងការចរចារអំពីតម្លៃ ដើម្បីលក់ផលិតផលបានតម្លៃខ្ពស់។
- **សហគមន៍នេសាទក្នុងខេត្តកោះកុង សរុបចំនួន១០សហគមន៍៖**
  - សហគមន៍នេសាទឃុំជ្រោយស្វាយ មានផ្ទៃទឹក សរុបចំនួន១៣.៤៤៣ហ.ត
  - សហគមន៍នេសាទតំបន់ឆ្នេរសមុទ្រកោះខ្យង មានផ្ទៃទឹក សរុបចំនួន៦.៤៦២ហ.ត
  - សហគមន៍នេសាទឃុំកណ្តោល មានផ្ទៃទឹក សរុបចំនួន២.៥៦០ហ.ត
  - សហគមន៍នេសាទតំបន់ឆ្នេរសមុទ្រតាមាយ មានផ្ទៃទឹក សរុបចំនួន៩.៣៩៤ហ.ត
  - សហគមន៍នេសាទតំបន់ឆ្នេរសមុទ្រថ្មស មានផ្ទៃទឹក សរុបចំនួន១១.២២០ហ.ត
  - សហគមន៍នេសាទសម្រស់កោះស្តេច មានផ្ទៃទឹក សរុបចំនួន១៦.១៥៨ហ.ត
  - សហគមន៍នេសាទឃុំភ្ញីមាស មានផ្ទៃទឹក សរុបចំនួន ៤.៨០៨ហ.ត
  - សហគមន៍នេសាទឃុំព្រែកខ្សាច់ មានផ្ទៃទឹក សរុបចំនួន៩.៧៣៨ហ.ត
  - សហគមន៍នេសាទឃុំជ្រោយប្រស់ មានផ្ទៃទឹក សរុបចំនួន១១.០៨៥ហ.ត
  - សហគមន៍នេសាទតំបន់ឆ្នេរសមុទ្រឃុំពាមក្រសោប មានផ្ទៃទឹក សរុបចំនួន២.២៧២ហ.ត។
  - បច្ចុប្បន្នកំពុងរៀបចំបង្កើតសហគមន៍នេសាទថ្មី ចំនួន៤ទៀត នៅតាមប្រព័ន្ធព្រែកស្រែអំបិល។

## ៧. ការងារអភិវឌ្ឍន៍ជនបទ

| ល.រ | ការបរិយាយ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | ចែកបង្គន់អនាម័យ | បង្គន់ | ៣៥០ | ២១៥ | ២២២ | ១៣៣ | ១៧៣ | ១.០៩៣ |
| ២ | សាងសង់អណ្តូងទឹក | អណ្តូង | ៥ | ១៣ | ០ | ២ | ០ | ២០ |
| ៣ | សាងសង់ស្រះទឹក | ស្រះ | ១ | ០ | ០ | ១ | ១ | ៣ |
| ៤ | សាងសង់ប្រព័ន្ធចែកចាយទឹក | កន្លែង | ០ | ០ | ០ | ១ | ១ | ២ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៥ | ថែទាំផ្លូវលក្ខណៈប្រចាំ | ម៉ែត្រ | ៣៧.២០០ | ៥៣.៧៩០ | ៦៩.០០០ | ២៧.៤០០ | ៩៦.៤០០ | ២៨៣.៧៩០ |
| ៦ | ថែទាំផ្លូវលក្ខណៈខួប | ម៉ែត្រ | ១៥.០០០ | ១៣.០៥០ | ១៤.៥០០ | ១០.៨០០ | ៨.០០០ | ៦១.៣៥០ |
| ៧ | ថែទាំផ្លូសជុលបន្ទាន់ | ម៉ែត្រ | ៤.៨០០ | ៤.៦០០ | ៧.៧០០ | ៧.៨៥០ | ៦.០០០ | ៣០.៩៥០ |
| ៨ | ការងារសាងសង់លូប្រអប់ | កន្លែង | ០ | ០ | ០ | ១ | ១ | ២ |
| ៩ | ការងារសាងសង់លូមូល | កន្លែង | ៥ | ០ | ០ | ១ | ៤ | ១០ |

### ៨. ការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត

| ល.រ. | ការបរិយាយ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|---|---|
| ២ | ការផ្តល់ច្បាប់អនុញ្ញាតសាងសង់ | គម្រោង | ១០៣ | ៥៨ | ៥២ | ២៩ | ៤២ | ២៨៤ |
| ៣ | ការចុះពិនិត្យសំណង់គ្មានច្បាប់ | ការដ្ឋាន | ១៥ | ១០ | ១១ | ៧ | ៨ | ៥១ |
| ៤ | ការចេញវិញ្ញាបនបត្រក្រុមជាង | ប័ណ្ណ | ១៣ | ១ | ២ | ៤ | ៤ | ២៤ |
| ៥ | ការធ្វើផែនការប្រើប្រាស់ដី | ឃុំ | ១ | ០ | ១ | ១ | ១ | ៤ |
| ៦ | ការធ្វើប្លង់គោលក្រុងខេមរភូមិន្ទ | ក្រុង | ០ | ១ | ០ | ០ | ០ | ១ |
| ៧ | ការផ្តល់ច្បាប់អនុញ្ញាតអភិវឌ្ឍនដី | គម្រោង | ០ | ០ | ១ | ៤ | ៥ | ១០ |
| ៨ | ការចុះបញ្ជីដីធ្លីលក្ខណៈដាច់ដោយដុំ | ប័ណ្ណ | ៣០ | ៣០ | ៤២ | ៦៦ | ៩៩ | ២៦៧ |
| ៩ | ការចុះបញ្ជីដីធ្លីតាមបទបញ្ជាលេខ០១បប | ប័ណ្ណ | ០ | ០ | ០ | ០ | ៤.៧៤៥ | ៤.៧៤៥ |
| ១០ | ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ | ប័ណ្ណ | ០ | ៤.៥៩៧ | ០ | ៣.៦៦៦ | ៦.១៨៨ | ១៤.៤៥១ |
| ១១ | ការចុះបញ្ជីដីរដ្ឋ | ប័ណ្ណ | ៣ | ០ | ១២ | ១១ | ១ | ២៧ |
| ១២ | ការដោះស្រាយវិវាទដីធ្លី | ករណី | ០ | ០ | ០ | ៧ | ៥ | ១២ |
| ១៣ | ការចុះស្រង់សំណង់អនាធិបតេយ្យ តាមមាត់ព្រែកកោះប៉ោ | គ្រួសារ | ០ | ០ | ០ | ០ | ៤៥០ | ៤៥០ |

រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ៣០ អនក្របក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២១ ស្តីពីការធ្វើអនុប្បយោគផ្ទៃដីទំហំ ១២៨.៩២៨,៣៩ហិកតា ក្នុងតំបន់ការពារធម្មជាតិចំនួន ៨តំបន់ ក្នុងភូមិសាស្ត ខេត្តកោះកុង ជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងមួយ ចំណែករក្សាទុកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋកាន់កាប់ដោយរដ្ឋបាលខេត្តកោះកុង។

រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ៤៦ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១ ស្តីពីការធ្វើ អនុប្បយោគផ្ទៃដីទំហំ ២៣.០៩២ហិកតា ក្នុងតំបន់ដីគម្របព្រៃឈើឆ្នាំ២០០២ និងតំបន់សម្បទានដី សេដ្ឋកិច្ចរបស់ក្រុមហ៊ុនហ្គ្រីនរិចគ្រុប ក្នុងភូមិសាស្រ្តខេត្តកោះកុង ជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដើម្បី ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងមួយចំណែករក្សាទុកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋកាន់កាប់ដោយរដ្ឋបាលខេត្តកោះកុង។

### ៩. ការងារសាធារណការ និងដឹកជញ្ជូន

| ល.រ | ការបរិយាយ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | ផ្លូវកៅស៊ូ | គ.ម | ៦,៧០ | ២,២០ | ០ | ៦,១១ | ៤,៥០ | ១៩,៥១ |
| ២ | ផ្លូវបេតុង | គ.ម | ០ | ១,២៥ | ១,១៥ | ០ | ០ | ២,៤០ |
| ៣ | ផ្លូវក្រាលគ្រួស | គ.ម | ០ | ០,៨០ | ០,៨០ | ០ | ០ | ១,៦០ |
| ៤ | លូមូលកាត់ទទឹងផ្លូវ | កន្លែង | ១០ | ០ | ០ | ៤៨ | ០ | ៥៨ |
| ៥ | លូប្រអប់កាត់ទទឹងផ្លូវ | កន្លែង | ០ | ២៤ | ៣៦ | ០ | ០ | ៦០ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៦ | ដាក់រីហ្កា | កន្លែង | ០ | ២ | ០ | ០ | ០ | ២ |

- កំពុងតែបន្តការសាងសង់ ផ្លូវជាតិលេខ១០ មានទីតាំងខេត្តកោះកុង ពោធិ៍សាត់ បាត់ដំបង ដោយចេញពីទីរួមខេត្តកោះកុង កាត់តាមផ្លូវទំនប់វារីអគ្គិសនីឫស្សីជ្រុំ និងទំនប់វារីអគ្គិសនីអាតៃ មកអូរសោម វាលវែង ទៅសំឡូត មានប្រវែង១៩៧,៣៧គ.ម ទទឹងផ្លូវ៩ម ក្រាលកៅស៊ូពីរស្រទាប់៨ម (DBST) សម្រេចបាន ៦៩.២៨%
- កំពុងបន្តការសាងសង់ផ្លូវជាតិលេខ៤៨ គម្រោងធ្វើឱ្យប្រសើរឡើងវិញនូវផ្លូវជាតិលេខ៤៨ មានទីតាំងស្ថិតនៅលើផ្លូវជាតិលេខ៤៨ ពីផ្លូវបំបែកស្រែអំបិល រហូតដល់គល់ស្ពានកោះកុងក្រុងខេមរភូមិន្ទ ខេត្តកោះកុង។ មានប្រវែងផ្លូវ១៥០គ.ម ប្រភេទផ្លូវក្រាលបេតុងកៅស៊ូ AC(Asphalt Concrete) និងក្រាលបេតុង(Concrete Cement) ត្រង់ផ្លូវប្រសព្វនឹងផ្លូវចំណោត សម្រេចបាន១៧,៩៧%
- ផ្លូវជាតិលេខ៤៨ និងស្ពានធំៗចំនួន៤ ជាសរសៃឈាមដ៏សំខាន់តភ្ជាប់ពីតំបន់នានាទូទាំងប្រទេស
- វិថីព្រឹទ្ធាចារ្យ សាយ ភូថង ត្រូវបានកសាងឡើងពីចំណុចផ្លូវបំបែកផ្លូវជាតិលេខ៤៨ ស្ថិតក្នុងឃុំអណ្តូងទឹក ស្រុកបូទុមសាគរ ឆ្ពោះទៅក្រុមហ៊ុន យូញៀន (UNION DEVELOPMENT Co., Ltd) ស្ថិតក្នុងឃុំកោះស្តេច ស្រុកគិរីសាគរ មានប្រវែង ៥៥គីឡូម៉ែត្រ
- ផ្លូវក្រាលក្រួសក្រហមបំបែកពីផ្លូវជាតិលេខ៤៨ ស្ថិតក្នុងឃុំត្រពាំងរូង ស្រុកកោះកុង មានប្រវែង ២៣.០០០ម៉ែត្រ
- បាននិងកំពុងកសាងស្ពានកោះយ៉ ស្ថិតក្នុងស្រុកមណ្ឌលសីមា
- បាននិងកំពុងសាងសង់កំពង់ផែទេសចរណ៍ ស្ថិតក្នុងក្រុងខេមរភូមិន្ទ។

**១០.ការងារធនធានទឹក និងឧតុនិយម**

| ល.រ | ការបរិយាយ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | ជួលជុលទំនប់ការពារទឹកប្រៃជីត្រេះ | ម | ៧.៨០០ | ០ | ០ | ០ | ០ | ៧.៨០០ |
| ២ | ជួលជុលទំនប់ការពារទឹកប្រៃដងពែង១ | ម | ០ | ៤.១០០ | ០ | ០ | ០ | ៤.១០០ |
| ៣ | ជួលជុលទំនប់ការពារទឹកប្រៃតាំកន់ | ម | ០ | ០ | ៦.៦៥០ | ០ | ០ | ៦.៦៥០ |
| ៤ | ជួលជុលទំនប់ការពារទឹកប្រៃតាំទៀក | ម | ០ | ០ | ០ | ៤.៦០០ | ០ | ៤.៦០០ |
| ៥ | ជួលជុលទំនប់ការពារទឹកប្រៃផ្លោង | ម | ០ | ០ | ០ | ០ | ៣.៧០០ | ៣.៧០០ |
| ៦ | ស្តារប្រឡាយ | ខ្សែ | ០ | ០ | ១ | ១ | ១ | ៣ |
| | ប្រវែង | ម | ០ | ០ | ៧.៨០០ | ៤.២៥០ | ៣.០០០ | ១៥.០៥០ |
| ៧ | ជួសជុលទ្វារអាងទឹកជិះត្រេះ | កន្លែង | ០ | ០ | ០ | ១ | ០ | ១ |
| ៨ | ថែទាំទំនប់ការពារទឹកប្រៃចំនួន | ខ្សែ | ៩ | ៩ | ៧ | ៦ | ៦ | |
| | ប្រវែង | ម | ២៦.៦៤១ | ២៦.៦៤១ | ២៧.៦១៩ | ៣០.១៣៩ | ២៦.០១៩ | |

**១១. ការងាររ៉ែ និងថាមពល**

| ល.រ | ការបរិយាយ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | ស្ថានីយវារីអគ្គិសនី | ទីតាំង | ៣ | ០ | ០ | ០ | ០ | ៣ |

<table>
<tr><td colspan="9">- វារីអគ្គិសនីស្ទឹងឫស្សីជ្រុំក្រោម មានអានុភាពជំឡើង៣៣៨មេហ្គាវ៉ាត់ វិនិយោគដោយក្រុមហ៊ុន China Huadian Lower Stung Russei Chrum Hydro-Electric Project (Cambodia) Company Limited ស្ថិតនៅឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង<br>- វារីអគ្គិសនីគិរីរម្យ៣ មានអានុភាពជំឡើង ១៨មេហ្គាវ៉ាត់ វិនិយោគដោយក្រុមហ៊ុន CETIC International Hydropower Development Co.,Ltd ស្ថិតនៅឃុំជងពែង ស្រុកស្រែអំបិល ខេត្តកោះកុង<br>- វារីអគ្គិសនីស្ទឹងតាតៃ មានអានុភាពជំឡើង២៤៦មេហ្គាវ៉ាត់ វិនិយោគដោយក្រុមហ៊ុន CambodiaTatayHydropower Limited (CTHL) ស្ថិតនៅក្នុងឃុំឫស្សីជ្រុំ និងឃុំទទៃលើ ស្រុកថ្មបាំង ខេត្តកោះកុង។</td></tr>
<tr><td>២</td><td>រោងចក្រអគ្គិសនីដើរដោយធ្យូងថ្ម</td><td>ទីតាំង</td><td>០</td><td>០</td><td>១</td><td>០</td><td>០</td><td>១</td></tr>
<tr><td colspan="9">- រោងចក្រអគ្គិសនីដើរដោយធ្យូងថ្ម (អនុភាព ៧០០ MW) កំពុងធ្វើការសាងសង់ ដោយក្រុមហ៊ុនក្រុមហ៊ុន រ៉ូយ៉ាល់ គ្រុម ខូ អិល ធី ឌី មានទីតាំង ស្ថិតនៅភូមិថ្មស និងភូមិចំលងគោ ឃុំថ្មស ស្រុកបូទុមសាគរ</td></tr>
<tr><td>៣</td><td>អនុស្ថានីយអគ្គិសនី</td><td>ទីតាំង</td><td>២</td><td>០</td><td>១</td><td>០</td><td>១</td><td>៤</td></tr>
<tr><td colspan="9">- អនុស្ថានីយអគ្គិសនី ក្រុងខេមរភូមិន្ទ (GS៥១) មានអនុភាព ៥0MW ស្ថិតនៅ ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា<br>- អនុស្ថានីយអគ្គិសនី កោះកុង (GS៥២) ស្ថិតនៅ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ (ផ្លូវ២៩៧)<br>- អនុស្ថានីយតាតៃ (GS២៥) ស្ថិតនៅវារីអគ្គិសនីតាតៃ ស្ថិតនៅក្នុងឃុំឫស្សីជ្រុំ និងឃុំទទៃលើ ស្រុកថ្មបាំង<br>- អនុស្ថានីយបូទុមសាគរ (GS៤៦) ស្ថិតនៅឃុំអណ្តូងទឹក ស្រុកបូទុមសាគរ ។</td></tr>
<tr><td>៤</td><td>សេវាករផ្គត់ផ្គង់ ចែកចាយអគ្គិសនី</td><td>សេវាករ</td><td>៨</td><td>១</td><td>០</td><td>១</td><td>១</td><td>១១</td></tr>
<tr><td>៥</td><td>ថាមពលអគ្គិសនីដែលផលិតបាន ឬទិញ</td><td>kwh</td><td>៦៤.២៥៤.១២៥</td><td>៨១.៤០៧.១៦៨</td><td>៩៨.២៧៨.០២៤</td><td>៩៦.១៤៧.៨៧២</td><td>១២០.៣១៥.៧៧៤</td><td>៤៦០.៤០២.៩៦៣</td></tr>
<tr><td>៦</td><td>ចំនួនភូមិដែលមានអគ្គិសនីប្រើប្រាស់</td><td>ភូមិ</td><td>៨៧</td><td>៥</td><td>១០</td><td>២</td><td>២</td><td>១០៦</td></tr>
<tr><td>៧</td><td>ភាគរយភូមិដែលមានអគ្គិសនីប្រើប្រាស់</td><td>%</td><td>៧៣,៧៣</td><td>៤,២០</td><td>៨,៤០</td><td>១,៦៨</td><td>១,៦៨</td><td>៨៩,០៨</td></tr>
<tr><td>៨</td><td>ចំនួនផ្ទះដែលមានអគ្គិសនីប្រើប្រាស់</td><td>កុងទ័រ</td><td>១៧.៣២៧</td><td>១.៤៣២</td><td>២.៥០៥</td><td>១.១៤០</td><td>២.៨៩៦</td><td>២៥.៣០០</td></tr>
<tr><td>៩</td><td>ស្ថានីយប្រេងឥន្ធនៈ ស្ថានីយឧស្ម័នឥន្ធនៈ និងស្ថានីយរួមប្រេង និងឧស្ម័នឥន្ធនៈ</td><td>ទីតាំង</td><td>៣០</td><td>៥</td><td>៣</td><td>៧</td><td>០</td><td>៤៥</td></tr>
<tr><td>១០</td><td>មណ្ឌលសន្និធិប្រេងឥន្ធនៈ</td><td>ទីតាំង</td><td>២</td><td>០</td><td>០</td><td>០</td><td>០</td><td>២</td></tr>
<tr><td>១១</td><td>ខ្សាច់សំណង់</td><td>ម៣</td><td>៥០.៣១៤</td><td>១៣៤.២៥២</td><td>៧៣៥.៥៧០</td><td>៧៦.៦៨០</td><td>៥៤១.៩៨៤</td><td>១.៥៣៨.៨០០</td></tr>
<tr><td>១២</td><td>ដីល្បាយខ្សាច់</td><td>ម៣</td><td>០</td><td>០</td><td>០</td><td>២៧៥.000</td><td>១២៥.000</td><td>៤00.000</td></tr>
<tr><td>១៣</td><td>ដីក្រហម</td><td>ម៣</td><td>៣៤.០១០</td><td>៥១.៧៨៦</td><td>៥៧.៤៩៥</td><td>១៦.000</td><td>១១.៧៥០</td><td>១៧១.០៤១</td></tr>
<tr><td>១៤</td><td>អាចម៍ដី</td><td>ម៣</td><td>០</td><td>៦៨.៩៤០</td><td>៤៨.២០០</td><td>៧៤.៨00</td><td>៥៥.៩00</td><td>២៤៧.៨៤០</td></tr>
<tr><td>១៥</td><td>ខ្សាច់សនាំចេញទៅក្រៅប្រទេស</td><td>តោន</td><td>៨៥៤.000</td><td>២៤៨.000</td><td>០</td><td>០</td><td>០</td><td>១.១០២.000</td></tr>
<tr><td>១៦</td><td>ខ្សាច់សផលិតកញ្ចក់ក្នុងស្រុក</td><td>តោន</td><td>០</td><td>០</td><td>០</td><td>០</td><td>៥.000</td><td>៥.000</td></tr>
</table>

## ១២.ការងារឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

| ល.រ | បរិយាយ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | បរិមាណផលិតទឹកស្អាត | $ម^{៣}$ | ១.៨៧៦.៨៦០ | ១.៩៣២.៦៦១ | ២.២២៤.៤៦២ | ២.៧៧០.៣៩០ | ៣.៣៤៣.៤៦០ | ៩.១៥០.២៤០ |
| ២ | ប្រវែងបណ្តាញ | គ.ម | ១៥ | ២០ | ៣៦ | ២៧ | ៥៩ | ១៥៧ |
| ៣ | ចំនួនគ្រួសារដែលទទួលបានទឹកស្អាតប្រើប្រាស់ | % | ៣០ | ៣៥ | ៣៨ | ៤០ | ៤២ | ៣៧ |
| ៤ | ក្រុមហ៊ុនផ្គត់ផ្គង់ទឹកស្អាត | ក្រុមហ៊ុន | ៣ | ០ | ០ | ០ | ០ | ៣ |
| -មានក្រុមហ៊ុន L.Y.P Group មានទីតាំងផលិតនៅភូមិបឹងយុនឆាង សង្កាត់ស្មាច់មានជ័យ ក្រុង ខេមរភូមិន្ទ ខេត្តកោះកុង វិនិយោគផ្នែកទឹកស្អាត បានគ្របដណ្តប់បានចំនួន 0៣សង្កាត់ និង១១ភូមិ ដែលមានបណ្តាញមេស្មើនិង ៥៨.៧៨0ម។ ក្រុមហ៊ុនបានកសាងទំនប់ស្ទាក់ទឹកជ្រោះតាប៉ន ដែលមានចំងាយពីទីរួមខេត្ត ៧គម ដែលស្ថិតនៅភូមិបឹងយុនឆាង សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ដែលអាចផ្ទុកទឹកបានកម្ពស់២៥m និងអាចស្តុកទឹកបានប្រហែលជា ៣លានម៣ និងមានអាងប្រព្រឹត្តកម្ម ចំនួន២ ដែលអាចស្តុកទឹកបាន ចំនួន២0.000ម៣<br>-មានក្រុមហ៊ុនលោក កើត ព្រហស្លវៈ មានទីតាំងផលិតនៅភូមិបឹងព្រាវ ឃុំបឹងព្រាវ ស្រុកស្រែអំបិល ខេត្តកោះកុង វិនិយោគផ្នែកទឹកស្អាត គ្របដណ្តប់បាន ចំនួន២ឃុំ និង ៦ភូមិ ដែលមានបណ្តាញមេ ៣១គម<br>-មានក្រុមហ៊ុនលោកស្រី ហុង មុំ មានទីតាំងផលិតនៅភូមិថ្មស ឃុំថ្មស ស្រុកមណ្ឌលសីមា ខេត្តកោះកុង វិនិយោគផ្នែកទឹកស្អាត គ្របដណ្តប់បាន ចំនួន២ភូមិ ដែលមានបណ្តាញមេ ៤គ.ម។ | | | | | | | | |
| ៥ | ស្ថិតិរោងចក្រ | មូលដ្ឋាន | ៧ | ០ | +១ | ០ | +១ | ៩ |
| ៦ | ស្ថិតិសហគ្រាសធុនតូច និងមធ្យម | មូលដ្ឋាន | ១២ | +៥ | ០ | +៤ | -៣ | ១៨ |
| ៧ | ស្ថិតិសិប្បកម្ម | មូលដ្ឋាន | ២៧៧ | +១៤ | +៨ | +១២ | +២ | ៣១៣ |
| ៨ | កម្លាំងពលកម្ម | នាក់ | ១១.៥៩៨ | +១.០០៨ | -៩៤៦ | +២៩៣ | +២១៩ | ១២.១៧២ |

## ១៣. ការងារបរិស្ថាន

| ល.រ | ការបរិយាយ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | ការគ្រប់គ្រង ការប្រមូលសំរាម | ក្រុមហ៊ុន | ៣ | ០ | ០ | ០ | ១ | ៤ |
| ២ | ទីលានចាក់សំរាម | កន្លែង | ៣ | ០ | ០ | -១ | ១ | ៣ |
| ៣ | សាងសង់ស្នាក់ការឧទ្យានុរក្ស | ខ្នង | ០ | ១ | | ១ | ៣ | ៥ |
| ៤ | សាងសង់បង្គន់អនាម័យ | បង្គន | ០ | ១០០ | ២៥០ | ២៧០ | ៥០ | ៦៧០ |
| ៥ | សាងសង់ទំនប់ការពារទឹកប្រៃ | កន្លែង | ២ | ០ | ០ | ០ | ០ | ២ |
| ៦ | ការដាំស្តារកូនកោងកាង | ដើម | ៦៩៦.២០០ | ១១.២០០ | ១៨៩០ | ២១៧.០០០ | ១.០០០ | ៩២៧.<br>២៩០ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ៧ | បោះបង្គោលព្រំប្រទល់រវាងដីអភិរក្ស និងដីអនុក្រឹត្យលេខ ៣០អនក្រ.បក | ដើម | ០ | ០ | ៣១៦ | ០ | ៥៩០ | ៩០៦ |
| ៨ | បោះបង្គោលព្រំប្រទល់សហគមន៍តំបន់ការពារធម្មជាតិ | ដើម | ០ | ៣៥ | ៣២៧ | ២១ | ០ | ៣៨៣ |
| ៩ | អណ្តូងលូ | អណ្តូង | ០ | ០ | ៥០ | ៥០ | ០ | ១០០ |
| ១០ | អណ្តូងស្នប់ | អណ្តូង | ០ | ០ | ០ | ៣៨ | ០ | ៣៨ |
| ១១ | ថ្នាលបណ្តុះកូនឈើ | ថ្នាល | ០ | ០ | ០ | ៣ | ០ | ៣ |
| ១២ | ជីកស្រះទឹក ទំហំ៨០ម x ១០០ម | កន្លែង | ១ | ០ | ០ | ០ | ០ | ១ |

ខេត្តកោះកុងមានតំបន់ការពារធម្មជាតិចំនួន១០តំបន់ ដែលមានផ្ទៃដីសរុបចំនួនជាង១លានហិកតា រួមមានៈ

**ក. ឧទ្យានជាតិជួរភ្នំក្រវាញខាងត្បូង** ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ៨៩.អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦។ គ្របដណ្តប់លើ ០៤ខេត្តគឺ កោះកុង ពោធិ៍សាត់ កំពង់ស្ពឺ និង ព្រះសីហនុ មានផ្ទៃដីសរុប ៤១០ ៣៩២ ហិកតា។ គ្របដណ្តប់លើខេត្តកោះកុងទំហំ ៣៦០ ៥៩៤ ហិកតា។

**ខ. ឧទ្យានជាតិជួរភ្នំក្រវាញកណ្តាល** ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ៨១.អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦។ គ្របដណ្តប់លើ ០៣ខេត្តគឺ កោះកុង ពោធិ៍សាត់ និងកំពង់ស្ពឺ មានផ្ទៃដីសរុប ៤០១៣១៣ ហិកតា។គ្របដណ្តប់លើខេត្តកោះកុងទំហំ ២៣១៦០៧ ហិកតា

**គ. ដែនជម្រកសត្វព្រៃតាតៃ** ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ៨០.អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ គ្របដណ្តប់លើ ០៤ស្រុក និង០១ក្រុងនៃខេត្តកោះកុងគឺ កោះកុង បុទុមសាគរ មណ្ឌលសីមា ថ្មបាំង និង ក្រុងខេមរភូមិន្ទ មានផ្ទៃដីសរុប ១៤៤២៧៥ ហិកតា។

**ឃ.របៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ (ជួរភ្នំក្រវាញ)** ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី ២៦ ខែមករា ឆ្នាំ២០១៧ មានផ្ទៃដីសរុប ១៦៩៤៦៩ ហិកតា គ្របដណ្តប់លើខេត្តកោះកុងទំហំដី ១៣១២១ហិកតា

**ង.ឧទ្យានជាតិសមុទ្រកោះរ៉ុង** ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០១៨ គ្របដណ្តប់លើ០២ខេត្តគឺៈ កោះកុង និង ព្រះសីហនុ មានផ្ទៃដីសរុប ៥២៤៤៨ ហិកតា។

**ច.ឧទ្យានជាតិបុទុមសាគរ** ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ គ្របដណ្តប់លើ០៣ស្រុកនៃខេត្តកោះកុងគឺ គិរីសាគរ កោះកុង និងបុទុមសាគរ មានផ្ទៃដី សរុប ១៧១២៥០ ហិកតា។

**ឆ. តំបន់ប្រើប្រាស់ច្រើនយ៉ាងដងពែង** ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ គ្របដណ្តប់លើ០២ស្រុកនៃខេត្តកោះកុងគឺ ស្រែអំបិល និងបុទុមសាគរ មានផ្ទៃដីសរុប ២៧៧០០ ហិកតា។

**ជ. ដែនជម្រកសត្វព្រៃពាមក្រសោប និងតំបន់រ៉ាមសារកោះកាពិ** ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣។ គ្របដណ្តប់លើ០២ស្រុក និង ០១ក្រុង នៃខេត្តកោះកុងគឺ មណ្ឌលសីមា កោះកុង និង ក្រុងខេមរភូមិន្ទ មានផ្ទៃដីសរុប ២៣៧៥០ ហិកតា។

**ឈ. ដែនជម្រកសត្វព្រៃភ្នំសំកុស** ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣។ គ្របដណ្តប់លើ០២ខេត្តគឺ កោះកុង និងពោធិ៍សាត់។គ្របដណ្តប់លើខេត្តកោះកុងទំហំដីសរុប ១៦៦៧០ហិកតា

### ១៤. ការងារធនាគារ

| ល.រ | ការបរិយាយ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | ធនាគារពាណិជ្ជ | ចំនួន | ៤ | +១ | +១ | +១ | +១ | ៨ |
| ២ | គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ | ចំនួន | ៥ | +០ | +០ | +០ | +១ | ៦ |

**ក. ធនាគារពាណិជ្ជ**

១. ធនាគារអេស៊ីលីដា ភីអិលស៊ី
២. ធនាគារកាណាឌីយ៉ា
៣. ធនាគារកម្ពុជាសាធារណៈ
៤. ធនាគារស្ថាបនា
៥. ធនាគារ ABA
៦. ធនាគារប្រៃសនីយកម្ពុជា
៧. ធនាគារអ៊ូរី
៨. ធនាគារហត្ថាកសិករ

**ខ. គ្រឹះស្ថានធនាគារហិរញ្ញវត្ថុ**

១. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់
២. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអេ អ៊ឹម ខេ
៣. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ LOLC
៤. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនិរន្ត៍
៥. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហត្ថាកសិករ
៦. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមហានគរ

### ១៥.ការងារប្រៃសណីយ៍ និងទូរគមនាគមន៍

| ល.រ | ការបរិយាយ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | មានប្រតិបត្តិករក្រុមហ៊ុនបញ្ញើប្រៃសណីយ៍ ក្នុងខេត្តកោះកុង ចំនួន៨ក្រុមហ៊ុន | ក្រុមហ៊ុន | ១ | ០ | ៥ | ១ | ១ | ៨ |
| ២ | មានប្រតិបត្តិករក្រុមហ៊ុនទូរស័ព្ទចល័ត ចំនួន៤ក្រុមហ៊ុន | ក្រុមហ៊ុន | ៤ | ០ | ០ | ០ | ០ | ៤ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៣ | មានប្រតិបត្តិករក្រុមហ៊ុនទូរស័ព្ទ អចល័តចំនួន ២ក្រុមហ៊ុន | ក្រុមហ៊ុន | ២ | ០ | ០ | ០ | ០ | ២ |
| ៤ | មានទីតាំងស្ថានីយ៍វិទ្យុទាក់ទង ប្រភេទ VHF | គ្រឿង | ២៧ | ០ | ០ | ០ | ០ | ២៧ |
| ៥ | មានហាង/តូបលក់ឬជួសជុលទូរស័ព្ទ | ទីតាំង | ០ | ២៥ | ០ | ០ | ០ | ២៥ |
| ៦ | មានហាង/តូបលក់ឬជួសជុលកុំព្យូទ័រ | ទីតាំង | ០ | ៤ | ០ | ០ | ០ | ៤ |

**១៦. ការងារធម្មការ និងសាសនា**

| ល.រ | ការបរិយាយ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | បានបង្កើតវត្តថ្មីគណៈធម្មយុត្តិកនិកាយ | វត្ត | ១ | ០ | ០ | ០ | ១ | ២ |
| ២ | ស្ទូវវៃថ្វាយបង្គំសាសនាឥស្លាម | ស៊ូរ៉ាវ | ០ | ០ | ០ | ០ | ១ | ១ |
| ៣ | វិហារថ្វាយបង្គំគ្រីស្ទសាសនា | វិហារ | ០ | ០ | ០ | ០ | ១ | ១ |

**១៧. ការងារផែនការ**

| ល.រ | ការបរិយាយ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | ធ្វើបច្ចុប្បន្នភាពទិន្នន័យគ្រួសារក្រីក្រ | សរុបគ្រួសារ | ៥.៧៨៩ | - | ៧.៨៤០ | +១.០៩៥ | - | ៨.៩៣៥ |
| | | គ្រួសារក្រ១ | ២.៤៣៦ | - | ២.៧៨០ | +៦១០ | - | ៣.៣៩០ |
| | | គ្រួសារក្រ២ | ៣.៣៥៣ | - | ៥.០៦០ | +៤៨៥ | - | ៥.៥៤៥ |
| ២ | កំណត់អត្តសញ្ញាណកម្មគ្រួសារងាយរងហានិភ័យ | គ្រួសារ | - | - | - | - | ២.៣៤៥ | |

**១៨. ការងារអត្តសញ្ញាណកម្ម**

| ល.រ | ការបរិយាយ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | អត្តសញ្ញាណប័ណ្ណ | សន្លឹក | ៣.២៦៦ | ៤.០៩៦ | ៤.៤០៨ | ៣.០១៩ | ១០.៩៦០ | ២៥.៧៤៩ |
| ៣ | សៀវភៅគ្រួសារ (ក៤) | ក្បាល | ៤៥៧ | ១.០៤៤ | ១.០៧៣ | ១.០៣៣ | ៧៨៧ | ៤.៣៩៤ |

**១៩. ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

| ល.រ | ការបរិយាយ | ឯកតា | ២០១៨ | ២០១៩ | ២០២០ | ២០២១ | ២០២២ | សរុប |
|---|---|---|---|---|---|---|---|---|
| ១ | និវត្តជនជាអតីតមន្ត្រីរាជការស៊ីវិល | នាក់ | ០ | ២៩៦ | ២៩៦ | ៣០២ | ៣០៥ | ១.១៩៩ |
| ២ | ជនបាត់បង់សម្បទាវិជ្ជាជីវៈអតីតមន្ត្រីរាជការស៊ីវិល | នាក់ | ០ | ១១ | ១១ | ១១ | ១០ | ៤៣ |
| ៣ | ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះក្រីក្រ | នាក់ | ០ | ៧០៣ | +១៩៨ | +២៨១ | -៤៥១ | ៧៣១ |
| ៤ | ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីក្រីក្រសម្រាល | នាក់ | ០ | ៩០៦ | -៥៦៣ | +២.១១១ | -២.១៨៨ | ៥.៧៦៨ |
| ៨០ | ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់កុមារអាយុក្រោម ២ឆ្នាំ គ្រួសារក្រីក្រ | នាក់ | ០ | ១៣៦៥ | +៦២២ | -១.៤៤២ | +១.០៤៣ | ១.៥៨៨ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ៨១ | ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់គ្រួសារជនងាយរងគ្រោះក្នុងអំឡុងពេលកូវីដ-១៩ ក្រកម្រិត១ | គ្រួសារ | 0 | 0 | ៣.២៧៥ | -២២១ | ៣៥១ | ៣.៤០៥ |
| ៨២ | ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់គ្រួសារជនងាយរងគ្រោះក្នុងអំឡុងពេលកូវីដ-១៩ ក្រកម្រិត២ | គ្រួសារ | 0 | 0 | ៥.៥៦០ | -១.៦៧៩ | ២៧១ | ៤.១៥២ |

## IV. ការវិនិយោគ និងអភិវឌ្ឍន៍

ដោយផ្អែកលើកត្តាភូមិសាស្ត្រ និងប្រជាសាស្ត្រ បច្ចុប្បន្នខេត្តកោះកុង មានក្រុមហ៊ុនជាច្រើន បានដាក់ទុនវិនិយោគដូចខាងក្រោម៖

- **ក្រុមហ៊ុន ដែលបានវិនិយោគទៅលើវិស័យដំណាំកសិកម្ម-ឧស្សាហកម្ម និងដំណាំ កៅស៊ូ រួមមាន៖**
  - ក្រុមហ៊ុន LIM LONG Co.,Ltd ស្ថិតនៅឃុំដងពែង ស្រុកស្រែអំបិល
  - ក្រុមហ៊ុន L.Y.P Group Co.,Ltd ស្ថិតនៅឃុំអណ្តូងទឹក ស្រុកបូទុមសាគរ
  - ក្រុមហ៊ុន CAMAGRA INVESTMENT GROUP Co.,Ltd ឃុំដងពែង ស្រុកស្រែអំបិល
  - ក្រុមហ៊ុន GREEN RICH GROUP Co.,Ltd ស្ថិតនៅឃុំជ្រោយប្រស់ ស្រុកកោះកុង
  - ក្រុមហ៊ុន SINOMEIMINVESTMENT Co.,Ltd ឃុំអណ្តូងទឹកស្រុកបូទុមសាគរ
  - ក្រុមហ៊ុន KOH KONG SEZ Co.,Ltd នៅឃុំព្រែកខ្សាច់ ស្រុកគិរីសាគរ។
- **ក្រុមហ៊ុនដែលវិនិយោគលើវិស័យទេសចរណ៍មាន៖**
  - ក្រុមហ៊ុន UNION DEVELOPMENT GROUP Co.,Ltd អភិវឌ្ឍន៍លើវិស័យឧស្សាហកម្មទេសចរណ៍ (តំបន់វិស្សមកាលតារាសាគរ មានទីលានវាយកូនហ្គោល សណ្ឋាគារ បឹងកាឡូជាច្រើនកន្លែង កំពង់ផែទឹកជ្រៅ រួមជាមួយនឹងព្រលានយន្តហោះខ្នាតអន្តរជាតិ4F គម្រោងឈូងសមុទ្រវែង (Long Bay) ស្ថិតនៅស្រុកគិរីសាគរ និងស្រុកបូទុមសាគរ)
  - ក្រុមហ៊ុន JW CAMBODIA ECO HOLIDAY ស្ថិតនៅក្នុងស្រុកកោះកុង និងស្រុកគិរីសាគរ
  - ក្រុមហ៊ុន BEST TRANSPORT AND SERVICES Co.,Ltd ស្ថិតនៅកោះពុតសារកណ្តាល ឃុំភ្ញីមាស ក្នុងស្រុកគិរីសាគរ
  - ក្រុមហ៊ុន FULL MOON ISLAND Co.,Ltd ស្ថិតនៅប្រជុំកោះអំពិល ក្នុងស្រុកគិរីសាគរ
  - ក្រុមហ៊ុន GILLGANS ISLAND Co.,Ltd ស្ថិតនៅកោះសាមិត ឬកោះខ្មោច ក្នុងស្រុកគិរីសាគរ
  - ក្រុមហ៊ុន KOH SMACH ISLAND RESORT DEVELOPMENTS Co.,Ltd ស្ថិតនៅកោះស្មាច់ ក្នុងស្រុកគិរីសាគរ
  - ក្រុមហ៊ុន SHORELINE (CAMBODIA) INVESTMENT Co.,Ltd នៅឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា
  - ក្រុមហ៊ុន COAST DEVELOPMENT GROUP Co.,Ltd ស្ថិតនៅកោះម្នាស់ ប៉ែកខាងជើងកោះដំឡូងក្នុង និងកោះដំឡូងក្រៅ ក្នុងស្រុកគិរីសាគរ

- ក្រុមហ៊ុន PINEAPPLE DEVELOPMENT GROUP Co.,Ltd ស្ថិតនៅកោះម្នាស់ប៉ែកខាងត្បូង និងកោះតាទឹម ក្នុងស្រុកគិរីសាគរ
- ក្រុមហ៊ុន DIRACE INVESTMENT LIMITED ស្ថិតនៅកោះទទឹង ក្នុងស្រុកគិរីសាគរ។

- **ក្រុមហ៊ុនដែលបានវិនិយោគលើវិស័យថាមពល**
  - វារីអគ្គិសនីស្ទឹងឫស្សីជ្រុំក្រោម មានអានុភាពដំឡើង៣៣៨មេហ្គាវ៉ាត់ វិនិយោគដោយក្រុមហ៊ុន China Huadian Lower Stung Russei Chrum Hydro-Electric Project (Cambodia) Company Limited ស្ថិតនៅឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង
  - វារីអគ្គិសនីគិរីរម្យ៣ មានអានុភាពដំឡើង ១៨មេហ្គាវ៉ាត់ វិនិយោគដោយក្រុមហ៊ុន CETIC International Hydropower Development Co.,Ltd ស្ថិតនៅឃុំជងពែង ស្រុកស្រែអំបិល ខេត្តកោះកុង
  - វារីអគ្គិសនីស្ទឹងតាតៃ មានអានុភាពដំឡើង២៤៦មេហ្គាវ៉ាត់ វិនិយោគដោយក្រុមហ៊ុន CambodiaTatayHydropower Limited (CTHL) ស្ថិតនៅក្នុងឃុំឫស្សីជ្រុំ និងឃុំទទៃលើ ស្រុកថ្មបាំង ខេត្តកោះកុង។
- **ការវិនិយោគជាតំបន់សេដ្ឋកិច្ចពិសេស មានចំនួន៤ទីតាំង ៖**
  - តំបន់សេដ្ឋកិច្ចពិសេសកោះកុង ស្ថិតនៅភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង របស់ក្រុមហ៊ុន L.Y.P Group Co.,Ltd ។ បច្ចុប្បន្នមានរោងចក្រចំនួន ០៦រោងចក្រ គឺ ក្រុមហ៊ុនYAZAKI ក្រុមហ៊ុនHYUNDAI ក្រុមហ៊ុនKKN ក្រុមហ៊ុនMIKASA Sport និងក្រុមហ៊ុន HANA ក្រុមហ៊ុន ៩៩ អុឹមប្រយឌឺរី កោះកុង ឯ.ក (99 EMPRODERY KOH KONG Co., LTD) ដែលកំពុងដំណើរការរាល់ថ្ងៃមានបុគ្គលិកកម្មករដែលកំពុងបម្រើការងារមានចំនួន ១១.៤៤៣នាក់ (ដប់មួយពាន់ បួនរយសែសិបបីនាក់) ស្ត្រីចំនួន ៨.១០៨នាក់ (ប្រាំបីពាន់មួយរយប្រាំបីនាក់)
  - តំបន់សេដ្ឋកិច្ចពិសេស កែវ ស៊ួយឆេង ស្ថិតនៅជាប់តំបន់សេដ្ឋកិច្ចពិសេសកោះកុង ក្នុងភូមិសាស្ត្រភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង
  - តំបន់សេដ្ឋកិច្ចពិសេសកោះកុងអេសអ៊ីហ្សិត ខូអិលធីឌី (Koh Kong SEZ Co., LTD) ស្ថិតក្នុងឃុំកោះស្ដេច ស្រុកគិរីសាគរ ខេត្តកោះកុង
  - តំបន់សេដ្ឋកិច្ចពិសេសជ្រោយស្វាយ ស្ថិតនៅក្នុងភូមិសាស្ត្រភូមិនេសាទ ឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង របស់ក្រុមហ៊ុនឆកកំពង់សោម ដែលបច្ចុប្បន្នកំពុងតែស្ថាបនាផ្លូវចូល អគាររោងចក្រ អគារស្នាក់នៅរបស់បុគ្គលិក...។ល។
- **ខេត្តកោះកុង មានកោះតូចធំចំនួន ៣៥កោះ ក្នុងនោះមាន ៩កោះ ដែលមានផ្កាថ្ម ហើយក្នុងចំណោមកោះទាំងអស់មាន ១៧កោះ ត្រូវបានវិនិយោគដោយក្រុមហ៊ុនចំនួន៩។**

## V. ទិសដៅការងារបន្ត

ទន្ទឹមនឹងលទ្ធផលការងារសម្រេចបានខាងលើ និងដើម្បីបន្តភាពរីកចម្រើនបន្តទៀតនោះ រដ្ឋបាលខេត្តបានដាក់ចេញនូវទិសដៅសម្រាប់អនុវត្តដូចតទៅ ៖

- បន្តពង្រឹងការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព
- ជំរុញការផ្តល់សេវារដ្ឋបាលសាធារណៈរបស់រដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ជូនប្រជាពលរដ្ឋ ឱ្យកាន់តែមានគុណភាព តម្លាភាព និងប្រសិទ្ធភាព
- បន្តខិតខំបណ្តុះបណ្តាលធនធានមនុស្សឱ្យបានកាន់តែច្រើន
- ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចខេត្ត ឱ្យសម្រេចបានកំណើនខ្ពស់ ស្របតាមគោលនយោបាយកាត់បន្ថយភាព ក្រីក្ររបស់រាជរដ្ឋាភិបាលឱ្យបានយ៉ាងតិច១%ក្នុងមួយឆ្នាំ
- ខិតខំអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់គ្រប់ប្រភេទទាំងផ្លូវទីប្រជុំជន និងផ្លូវជនបទ
- គ្រប់គ្រង និងអភិវឌ្ឍគោលដៅទេសចរណ៍សំខាន់ៗ កែលម្អសេវាទេសចរណ៍ និងបង្កើនផលិតផលទេសចរណ៍ អនុវត្តទិសដៅ នៃការអភិវឌ្ឍបៃតង ជំរុញចលនាប្រឡងប្រណាំងទីក្រុងស្អាត រមណីយ-ដ្ឋានស្អាត ទីក្រុងបៃតង បំផុសចលនាការបង្កើនអនាម័យ ការដាំដើមឈើជាដើម
- ខិតខំដោះស្រាយបញ្ហាលំបាកនានារបស់ប្រជាពលរដ្ឋ។

**អភិបាល**